ការកុហក

សំរាប់ក្មេងៗអាយុពី 3 ទៅ 5 ឆ្នាំ

ការកុហកគឺជាការធម្មតានៅក្នុងកុមារភាព ។ កុមារអាចនឹងនិយាយពន្លើស ឬផ្លាស់ប្តូរការពិត បង្កើតជារឿងផ្សេងៗ ឬប្រកែកនូវអ្វីៗដែលមនុស្ស ពេញវ័យដឹងថាជាពិត។ កប៉ុន្តែនេះមិនពិតជាការកុហកទេ។ ភាពខុសគ្នាគឺនៅលើចេតនា ។ ការកុហកពិតគឺនៅពេលនរណាម្នាក់ និយាយអ្វីមួយ ដែលគេដឹងថាជាការក្លែងក្លាយ ដើម្បីលាក់បាំងការពិត ។

តើហេតុអ្វីបានជាក្មេងៗកុហក?

នៅខាងក្រោមនេះគឺជាមូលហេតុមួយចំនួន ដែលក្មេងៗអាចនឹងកុហក :

ការភ័យខ្លាច ។
ក្មេងៗភ័យខ្លាចចំពោះការធ្វើឲ្យឪពុកម្តាយរបស់គេខកចិត្ត និងត្រូវបានទទួលទណ្ឌកម្ម ។ គេស្ទាន បើសិនជាគេពុំបានធ្វើអ្វីខុសទេ ឪពុកម្តាយរបស់គេនឹងមិនអាក់អន់ចិត្តឡើយ ហើយគេក៏នឹងមិនទទួលទណ្ឌកម្មដែរ ។

ការធ្វើត្រាប់តាម ។ ក្មេងៗឮមនុស្សពេញវ័យនិយាយកុហក ហើយគិតថាវាមិនថ្វីទេ ។ មនុស្សពេញវ័យអាចនឹងប្រាប់ "កុហកជាលេស" ឬផ្តល់ការដោះសារ សំរាប់មិនធ្វើការអ្វីមួយ ។ ក៏ប១ុន្តែក្មេងៗមិនដឹងភាពខុសគ្នានៃប្រភេទប្លែកពីគ្នានៃការកុហកឡើយ ។

ទម្លាប់ ។ ការកុហកអាចងាយក្លាយជាទម្លាប់ បើសិនជាបានធ្វើញឹកញាប់ច្រើនដងច្រើនសា ។

ការប្រាថ្នាចង់បានអ្វីៗដែលពិត ។
ក្មេងៗគ្រាន់តែចង់បានអ្វីៗដែលជាពិត ។ ការនិយាយស្តីឮៗជួយឲ្យក្មេងជឿបាន ។ ឧទាហរណ៍ នៅពេលកូនរបស់អ្នកនិយាយថា "ខ្ញុំមិនបានធ្វើអ្វីទេ" ហើយអ្នកដឹងថាគេបានធ្វើ ។

តើការកុហកគួរតែទទួលទណ្ឌកម្មឬទេ?
ឥតងាយធ្លើយចំពោះសំណួរនេះឡើយ ។ អ្នកដែលជាឪពុកម្តាយ អាចនឹងនិយាយថា អ្នកកំពុងតែដាក់ទណ្ឌកម្មកូនរបស់អ្នក សំរាប់ការកុហក ។ ក៏ប១ុន្តែកូនរបស់អ្នកអាចនឹងគិតថា ទណ្ឌកម្មគឺមិនមែនសំរាប់តែការកុហកប៉ុណ្ណោះទេ ប១ុន្តែសំរាប់ការដែលបានរកឃើញហេតុទេវិញ ។ បើសិនជា កូនរបស់អ្នកកុហក ពីព្រោះតែខ្លាចត្រូវបានដាក់ទណ្ឌកម្ម នោះការដាក់ទណ្ឌកម្មកូនរបស់អ្នក អាចនឹងធ្វើឲ្យកូនរបស់អ្នកកុហកកាន់តែច្រើនឡើងៗ នៅពេលអនាគត!

នៅពេលការកុហកមានភាពធ្ងន់ធ្ងរ

សំរាប់កុមារធំជាងនេះ

ជួនកាលការកុហកគឺជាសញ្ញាមួយដែលបង្ហាញថាមានអ្វីមួយដែលខុស ។ ក្មេងៗដែលកុហករាល់ពេលវេលា ក៏អាចនឹងមានបញ្ហាជាមួយនឹង :

- ការលួច និងការគៃបន្ទំ
- កំហឹង
- ការគេចវេះមិនទៅសាលា
- ការមានមិត្តភ័ក្តិ ឬមានស្ថានការណ៍សង្គមផ្សេងៗទៀត

ត្រូវពិគ្រោះជាមួយនឹងគ្រូពេទ្យនៃកូនរបស់អ្នក អំពីចំងល់ទាំងនេះ ។

តើមាតាបិតាអាចធ្វើអ្វីខ្លះ?

ត្រូវព្យាយាមរកមូលហេតុសំរាប់ការកុហក ។
ការនេះនឹងជួយអ្នកឲ្យដឹងថាត្រូវធ្វើអ្វីខ្លះអំពីរឿងនេះ ។

ត្រូវជួយកូនរបស់អ្នកឲ្យយល់នូវអ្វីៗដែលពិតជាបានកើតឡើង ។
ការប្រាថ្នាចង់បាន ឬការនិយាយអំពីអ្វីដែលពុំបានកើតឡើង នឹងមិនផ្លាស់ប្តូរ ហេតុការណ៍ដែលបានកើតឡើងទេ ។ ត្រូវព្យាយាមនិយាយថា "សូម្បីតែកូនថាកូនពុំបាននាំភាក់ចូលមកក្នុងផ្ទះក្តី ក៏កូនមើលចុះ គង់តែមានភាក់ ហើយស្បែកជើងរបស់កូនក៏ប្រឡាក់ភាក់ដែរ" ។

ត្រូវមានចិត្តល្អ នៅពេលកូនរបស់អ្នកធ្វើអ្វីខុសបន្តិចបន្តួច ។ ត្រូវជួយកូនរបស់អ្នកឲ្យឃើញការអ្វីដែលបានធ្វើខុស ប១ុន្តែត្រូវប្រាប់គេឲ្យដឹងថា គេអាចប្រាប់ការពិតបានដោយឥតមានទោសពៃរ៍អ្វីទេ ។ ត្រូវអះអាងដល់កូនរបស់អ្នកឡើងវិញ ថាអ្នកនឹងមិនខឹងទេ នៅពេលអ្នកឮមានរឿង អ្វីដែលពិតបានកើតឡើង ។

ប្រសិនជាកូនរបស់អ្នកធ្វើអ្វីខុស ត្រូវជួយកូនរបស់អ្នកដោះស្រាយបញ្ហានោះ ។
បើកូនរបស់អ្នកបាននាំភាក់មកចូលក្នុងផ្ទះ ត្រូវជូតសំអាតវា ទាំងអស់គ្នា ។ កូនរបស់អ្នកនឹងរៀនយល់ថា ភាក់ពិតជាបានវាប៉ាត់ប៉ាយនៅលើកំរាលផ្ទះមែន ។

ត្រូវកោតសរសើរកូនរបស់អ្នក សំរាប់ការប្រាប់នូវការពិត ។
ត្រូវជួយកូនរបស់អ្នកឲ្យយល់ នូវអ្វីៗដែលគេប្រហែលជាបានធ្វើខុស ប១ុន្តែការប្រាប់ នូវអំពីរឿងពិតនោះ គឺជាការល្អ ។ បើសិនជាកូនរបស់អ្នកសារភាពចំពោះការនាំភាក់ចូលមកក្នុងផ្ទះ អ្នកគួរតែនិយាយថា "សូមអរគុណកូន ដែលកូនប្រាប់ពុកមែ១អំពីការពិត ។ ប១ុន្តែកូនបានធ្វើឲ្យកំរាលផ្ទះប្រឡាក់ភាក់ ហើយកូននឹងត្រូវជួយពុកម៉ែជូតសំអាតវាឲ្យជ្រះ" ។

Developed by L.A. Care Health Plan working with our contracted health plan partners. Together, we provide Medi-Cal managed care services in Los Angeles County.

បានបង្កើតឡើងដោយគំរោងសុខភាព L.A. Care Health Plan ដោយធ្វើការជាមួយដៃគូគំរោងសុខភាពរបស់យើងដែលបានចុះកុងត្រា ។ ទាំងអស់គ្នា យើងផ្តល់នូវសេវា Medi-Cal ចាត់ចែងការថែទាំ នៅក្នុងខោនធីឡូសអង់ជីឡេស ។

LA0391 KH 01/08